01205349

E378/1

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 19 / 02 / 2016
ម៉ោង (Time/Heure) : 16:00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

## អង្គជំនុំជម្រះសាលាដំបូង

ថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០១៦

**ផ្ញើជូន៖** ប្រធានគណៈមេធាវីទីក្រុងអាំស្ទែរដាំ

**ពី៖** ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង

**ចម្លងជូន៖** លោក/លោកស្រីចៅក្រម, មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង និងគ្រប់ភាគីទាំងអស់ក្នុងសំណុំរឿង ០០២

**កម្មវត្ថុ៖** សេចក្តីបន្ថែម - កំហុសវិជ្ជាជីវៈដែលអាចមានរបស់មេធាវី ០១ រូបដែលបានចុះបញ្ជីនៅគណៈមេធាវីរបស់លោក/លោកស្រី - លោក Victor KOPPE

សូមយោងទៅសេចក្តីជូនដំណឹងចុះថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០១៥ (ឯកសារ E378) របស់អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) ទាក់ទងនឹងកំហុសវិជ្ជាជីវៈដែលអាចមានរបស់លោក Victor KOPPE ដែលជាមេធាវីការពារក្តីលោក នួន ជា នៅក្នុងសំណុំរឿង ០០២/០២។ នាពេលនេះ អង្គជំនុំជម្រះសូមជូនដំណឹងអំពីការប្រព្រឹត្តបន្ថែមទៀតរបស់លោក Victor KOPPE ចាប់តាំងពីថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០១៥ ដែលអង្គជំនុំជម្រះសាលាដំបូងយល់ថា អាចជាកំហុសវិជ្ជាជីវៈនៅចំពោះមុខ អ.វ.ត.ក ដូចដែលមានចែងនៅក្នុងវិធាន ៣៨ (១) នៃវិធានផ្ទៃក្នុង។

នៅក្នុងកិច្ចសម្ភាសន៍មួយដែលត្រូវបានបោះពុម្ពផ្សាយនៅក្នុង Mekong Review ចុះថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១៦ ដែលចេញផ្សាយរៀងរាល់បីខែម្តង លោក Victor KOPPE បានធ្វើការវាយប្រហារ ជាលក្ខណៈបុគ្គលជាសាធារណៈទៅអង្គជំនុំជម្រះសាលាដំបូង ជាពិសេស ចៅក្រម Jean-Marc Lavergne។ ផ្នែកខ្លះនៃការសម្ភាសន៍នោះត្រូវបានបោះពុម្ពផ្សាយសាជាថ្មីនាពេលក្រោយមកទៀតនៅក្នុងសារព័ត៌មាន The Cambodia Daily ចុះថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ២០១៦។

នៅក្នុងកិច្ចសម្ភាសន៍នោះ លោក Victor KOPPE បានលើកឡើង និង ផ្តល់យោបល់ដូចខាងក្រោម៖

- នៅពេលគេសួរថាតើគាត់នឹងកែប្រែការប្រព្រឹត្តិទេ គាត់បានឆ្លើយតបថា "អត់ទេ ខ្ញុំមើលងាយខ្លាំងចំពោះចៅក្រមបារាំង [ចៅក្រម Jean-Marc Lavergne]។ បើមានបញ្ហាអ្វីខ្លាំងទៅមុខទៀត ឱ្យទៅតាមដំណើរចុះ"[1]។
- នៅពេលគេសួរថាតើគាត់មានបញ្ហាអ្វីជាមួយចៅក្រមរូបនោះទេ គាត់ឆ្លើយថា "មាន"។ អ្នកសួរ លោក Bui Jones សួរថា "តើព្រោះតែគាត់ជនជាតិបារាំងមែនទេ"។ "[សើច] អត់ទេ មិនមែនដោយសារតែគាត់ជាជនបារាំងទេ។ អត់ទេ ខ្ញុំចូលចិត្តជនជាតិបារាំង។ វាងាយ
ណាស់។ គាត់ធ្វើអ្វីៗគ្រប់យ៉ាងដើម្បីរាំងខ្ញុំមិនឱ្យសួរសំណួរ។ គាត់ព្យាយាមរាំងមិនឱ្យមានការរៀបរាប់អំពីរឿងរ៉ាវ [របស់ នួន ជា][2]។
- "ពាក្យថា ៖ "ខ្ញុំគ្មានអ្វីក្រៅពីការមើលងាយផ្នែកវិជ្ជាជីវៈចំពោះចៅក្រមអន្តរជាតិ" គឺជាប្រយោគដែលខ្ញុំបានគិតគូរមុនពេលខ្ញុំនិយាយចេញ"។ នៅពេលគេសួរថាតើគាត់បានគិតពីការឆ្លើយតបទេ គាត់ឆ្លើយថា "បានគិត ខ្ញុំបានជ្រើសរើសពាក្យទាំងនេះដោយប្រុងប្រយ័ត្ន។ ខ្ញុំបានជ្រើសរើសពាក្យទាំងនេះ ពីព្រោះថា ពាក្យទាំងនេះធ្លាប់ជា ហើយនៅតែជា ពាក្យដែលខ្ញុំអាចនិយាយបានតែប៉ុណ្ណឹងក្នុងវិជ្ជាជីវៈ[3]។
- "ប្រសិនបើអ្នកចេញចូលនៅក្នុងបន្ទប់សវនាការ អ្នកដឹងថា... មិនអាចទ្រាំបានទេ ចេញចូលរាល់ថ្ងៃ ជួបចៅក្រមបារាំងរូបនោះ ដែលជារួមគឺលម្អៀង គ្មានសមត្ថភាព និង ល្ងង់។ អ្នកដទៃមិនដឹងថាវាលំបាកយ៉ាងណាទេ?"[4]។

---

[1] *Victor's justice* (Minh Bui Jones, Mekong Review) ខែ កុម្ភៈ - ខែ មេសា ឆ្នាំ ២០១៦។ សូមមើលផងដែរ *Defense Lawyer's Jibes at Judge Get personal in Interview* (George White, សារព័ត៌មាន The Cambodia Daily) ថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ២០១៦។

[2] *Victor's justice* (Minh Bui Jones, Mekong Review) ខែ កុម្ភៈ - ខែ មេសា ឆ្នាំ ២០១៦។ សូមមើលផងដែរ *Defense Lawyer's Jibes at Judge Get personal in Interview* (George White, សារព័ត៌មាន The Cambodia Daily) ថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ២០១៦។

[3] *Victor's justice* (Minh Bui Jones, Mekong Review) ខែ កុម្ភៈ - ខែ មេសា ឆ្នាំ ២០១៦។

[4] *Victor's justice* (Minh Bui Jones, Mekong Review) ខែ កុម្ភៈ - ខែ មេសា ឆ្នាំ ២០១៦។ សូមមើលផងដែរ *Defense Lawyer's Jibes at Judge Get personal in Interview* (George White, សារព័ត៌មាន The Cambodia Daily) ថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ២០១៦។

- នៅពេលដែលគេសួរថាតើនឹងមានបញ្ហាអ្វីចំពោះកំហុសឆ្គងរបស់គាត់ លោក Victor KOPPE បានឆ្លើយថា "តាមពិតទៅ ខ្ញុំមានការសង្ស័យលើចំណុចនេះ។ មេធាវីពីមុនមក [Pestman] និង Andrew Ianuzzi ត្រូវបានគេប្ដឹងទៅគណៈមេធាវីនៅទីក្រុងអាំស្ទែរដាំ និង
ញូវយ៉ក ខ្ញុំមិនគិតថា គណៈមេធាវីទាំងនោះបានឆ្លើយតបទេ។ ហេតុដូច្នេះ ដូចដែលខ្ញុំបានលើកឡើងនៅក្នុង [សារព័ត៌មាន] តាមពិតទៅ ខ្ញុំសប្បាយចិត្តដែរចំពោះចំណុចនេះ"[5]។

អង្គជំនុំជម្រះភ្ជាប់ជាមួយនឹងអនុស្សរណៈនេះនូវអត្ថបទដែលមានសម្រង់អត្ថបទខាងលើនេះ សម្រាប់ជាឯកសារយោង។

អង្គជំនុំជម្រះសាលាដំបូងស្នើសុំឱ្យមានការពិចារណាទៅលើការប្រព្រឹត្តិនេះ រួមជាមួយនឹងការចោទប្រកាន់ផ្សេងៗទៀតដែលមាននៅក្នុងសេចក្ដីជូនដំណឹងកាលពីថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០១៥។ អង្គជំនុំ-ជម្រះសូមជំរុញឱ្យមានការស៊ើបអង្កេតទៅលើបញ្ហានេះឱ្យបានទាន់ពេលវេលា ដើម្បីធានាឱ្យមានការចាត់ទុកបញ្ហានេះថា ជាបញ្ហាបន្ទាន់ ហើយត្រូវដោះស្រាយនៅក្នុងអំឡុងពេល អ.វ.ត.ក ដំណើរ
ការងារ។

អង្គជំនុំជម្រះសូមឱ្យមានការជូនដំណឹងឱ្យបានឆាប់ៗអំពីលទ្ធផលនៃសេចក្ដីជូនដំណឹងកាលពីថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០១៥ (ឯកសារ E378) និង ការជូនដំណឹងបន្ថែមនេះ និង វិធានការណាមួយចំពោះបញ្ហានេះ ដល់មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះ។

សូមទាក់ទងមកមន្ត្រីច្បាប់ខាងក្រោម ប្រសិនបើលោក/លោកស្រីមានជាសំណួរ ឬ ត្រូវការព័ត៌មានបន្ថែមពីអង្គជំនុំជម្រះ។

Ken Roberts (roberts13@un.org)
មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង
អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
ប្រអប់សំបុត្រលេខ ៧១ រាជធានីភ្នំពេញ ប្រទេសកម្ពុជា

---

[5] *Victor's justice* (Minh Bui Jones, Mekong Review) ខែ កុម្ភៈ - ខែ មេសា ឆ្នាំ ២០១៦។